អេភេសូរ១:១-៣

ជំពូក ១

ជាទូទៅ ក្រុមជំនុំគឺជារូបកាយនៃព្រះគ្រីស្ទ
ព្រះវរបិតាធ្វើគម្រោងបង្កើតឱ្យមានក្រុមជំនុំ
ព្រះរាជបុត្រាបង់ថ្លៃទិញក្រុមជំនុំ
ព្រះវិញ្ញាណបរិសុទ្ធថែរក្សាក្រុមជំនុំ
សាវ័កប៉ុលអធិស្ឋានជូនក្រុមជំនុំអេភេសូរ

គម្ពីរអេភេសូរចាប់ផ្តើមដោយវគ្គធំមួយ គឺវគ្គគោលទ្ធិស្តីពីការត្រាស់ហៅពីស្ថានលើដល់ក្រុមជំនុំរបស់ព្រះជាម្ចាស់។

**[1]សំបុត្រប៉ុលខ្ញុំ ជាសាវករបស់ផងព្រះយេស៊ូវគ្រីស្ទ ដោយនូវ
បំណងព្រះហឫទ័យព្រះ ផ្ញើមកពួកបរិសុទ្ធ ដែលនៅក្រុង
អេភេសូរ ជាពួកអ្នកស្មោះត្រង់ក្នុងព្រះគ្រីស្ទយេស៊ូវ [2]សូមឱ្យអ្នក
រាល់គ្នាបានប្រកបដោយព្រះគុណ នឹងសេចក្តីសុខសាន្ត អំពីព្រះ
ជាព្រះវរបិតានៃយើង ហើយអំពីព្រះអម្ចាស់យេស៊ូវគ្រីស្ទ
(អេភេសូរ១:១-២)។**

ខខាងលើ ជាសេចក្តីផ្តើមនៃសំបុត្ររបស់សាវ័កប៉ុលសរសេរទៅកាន់ពួកជំនុំនៅទីក្រុងអេភេសូរ។ សេចក្តីផ្តើមខាងលើ ខ្លីជាងសេចក្តីផ្តើមក្នុងសំបុត្រនានារបស់សាវ័កប៉ុល។ ឯមូលហេតុសេចក្តីផ្តើមនោះខ្លី ពីព្រោះសំបុត្រនោះមិនមែនសម្រាប់តែពួកជំនុំនៅទីក្រុងអេភេសូរតែប៉ុណ្ណោះទេ គឺសម្រាប់ពួកជំនុំដទៃៗទៀត ជារូបកាយរបស់ព្រះអម្ចាស់យេស៊ូវគ្រីស្ទជាក្រុមជំនុំសកល។ សំបុត្រសាវ័កប៉ុលសរសេរទៅកាន់ពួកជំនុំអេភេសូរ ជាសំបុត្រដែលព្រះវិញ្ញាណបរិសុទ្ធរបស់ព្រះអង្គប្រើសម្រាប់ពួកជំនុំរបស់ព្រះអង្គគ្រប់កាល:ទេស: គ្រប់កាលសម័យ គ្រប់វ័យជំនាន់។ សព្វថ្ងៃព្រះវិញ្ញាណបរិសុទ្ធព្រះអង្គប្រើសំបុត្រនេះ ដើម្បីមានបន្ទូលមកកាន់ពួកជំនុំនៅក្នុងជំនាន់យើងរស់នៅនេះដែរ។ ឥឡូវ សូមយើងធ្វើការសិក្សាគម្ពីរអេភេសូរយ៉ាងលំអិត។

"សំបុត្រប៉ុលខ្ញុំ ជាសាវករបស់ផងព្រះយេស៊ូវគ្រីស្ទ..."។ នៅក្នុងអត្ថបទដើមឃ្លានេះសម្តែងថា "សំបុត្រប៉ុលខ្ញុំ ជាសាវកមួយរូបក្នុងចំណោមសាវកឯទៀតនៃព្រះគ្រីស្ទយេស៊ូវ"។ សំបុត្រសាវ័កប៉ុលស្ទើរតែទាំងអស់ហៅព្រះអម្ចាស់យេស៊ូវគ្រីស្ទថា ព្រះគ្រីស្ទយេស៊ូវ។ ព្រះគ្រីស្ទ គឺជាតួនាទីរបស់ទ្រង់។ គម្ពីរម៉ាថាយ១៦:១៦សម្តែងថា "ស៊ីម៉ូន-ពេត្រុសទូលឆ្លើយថា ទ្រង់ជាព្រះគ្រីស្ទ ជាព្រះរាជបុត្រានៃព្រះដ៏មានព្រះជន្មរស់"។ យេស៊ូវ គឺនាមរបស់ទ្រង់ជាមនុស្សជាតិ។ ក្នុងគម្ពីរ២កូរិនថូស៥:១៦ សាវ័កប៉ុលបញ្ជាក់ថា "ចានជាពីនេះទៅមុខ យើងខ្ញុំមិនស្គាល់អ្នកណាខាងឯសាច់ឈាមទៀតទេ តែបើយើងខ្ញុំបានស្គាល់ព្រះគ្រីស្ទខាងសាច់ឈាមហើយ គង់តែឥឡូវនេះមិនស្គាល់ទ្រង់យ៉ាងនោះទៀតឡើយ"។ ចាប់ពីសាវ័កប៉ុលទទួលជឿព្រះអម្ចាស់យេស៊ូវជាអង្គ

សង្គ្រោះមក សាវ័កប៉ុលមិនបានស្គាល់ព្រះអម្ចាស់យេស៊ូវគ្រីស្ទ ត្រឹមតែជាមនុស្សដែលធ្វើការអស្ចារ្យចំនួនបីឆ្នាំកន្លះតែប៉ុណ្ណោះទេ។ លោកស្គាល់ព្រះអម្ចាស់យេស៊ូវគ្រីស្ទថាជាព្រះដ៏មានពោរពេញដោយសិរីល្អ។ ទ្រង់យាងមកជួបជាមួយនឹងសាវ័កប៉ុលផ្ទាល់តាមផ្លូវដែលលោកធ្វើដំណើរទៅទីក្រុងដាម៉ាស។ ដូច្នេះ កាលណានិយាយពីអង្គព្រះយេស៊ូវគ្រីស្ទ សាវ័កប៉ុលតែងតែនិយាយថា ព្រះគ្រីស្ទយេស៊ូវ។

មិនតែប៉ុណ្ណោះ សាវ័កប៉ុលបញ្ជាក់ថា លោកជាសាវ័ករបស់ព្រះអម្ចាស់យេស៊ូវគ្រីស្ទ។ សាវ័ក គឺជាអ្នកទទួលតួនាទីខ្ពង់ខ្ពស់ជាងគេបង្អស់នៅក្នុងចំណោមឥស្សរជនគ្រប់គ្រងក្រុមជំនុំ។ សព្វថ្ងៃនេះ មិនមានអ្នកណាម្នាក់មានសិទ្ធិបំពេញតួនាទីជាសាវ័ករបស់ព្រះអម្ចាស់យេស៊ូវគ្រីស្ទទេ។ ដើម្បីទទួលនាទីជាសាវ័ករបស់ព្រះអម្ចាស់យេស៊ូវគ្រីស្ទ សាវ័កប៉ុលបង្ហាញថា បុគ្គលម្នាក់ត្រូវមានលក្ខណៈគ្រាំមួយយ៉ាងដូចខាងក្រោមនេះ។ មួយ បុគ្គលនោះត្រូវទទួលការតែងតាំងដោយព្រះឱស្ឋរបស់ព្រះអម្ចាស់យេស៊ូវគ្រីស្ទផ្ទាល់។ លោកប៉ុលប្រកាសខ្លួនលោកផ្ទាល់ថា ព្រះអម្ចាស់យេស៊ូវបានតែងតាំងលោកពីព្រះឱស្ឋរបស់ទ្រង់ផ្ទាល់តែម្តង។ គម្ពីរកាឡាទី១:១ សាវ័កប៉ុលសម្តែងថា "សំបុត្រប៉ុលខ្ញុំ ដែលជាសាវ័ក មិនមែនអំពីមនុស្ស ឬដោយសារមនុស្សទេ គឺដោយសារព្រះយេស៊ូវគ្រីស្ទ នឹងព្រះជ៏ជាព្រះវរបិតា ដែលបានប្រោសឱ្យទ្រង់រស់ពីស្លាប់ឡើងនោះវិញ"។ ចំណុចនេះ នាំអោយខ្ញុំជឿថា លោកម៉ាត់ធាសមិនមែនជាអ្នកត្រូវជំនួសលោកយូដាស-អីស្ការីយ៉ុតទេ។ សាវ័កដែលចូលមកបំពេញតួនាទីជំនួសលោកយូដាស-អីស្ការីយ៉ុត គឺជាសាវ័កប៉ុល។ ព្រះអម្ចាស់យេស៊ូវគ្រីស្ទតែងតាំងសាវ័កប៉ុលដោយ

ព្រះឱស្ឋទ្រង់ផ្ទាល់។ ពីរ សាវ័កត្រូវឃើញព្រះអម្ចាស់យេស៊ូវគ្រីស្ទរស់ឡើងវិញផ្ទាល់នឹងភ្នែក។ លោកប៉ុលមានលក្ខណៈសម្បត្តិបែបនេះ។ បី សាវ័ក គឺជាអ្នកដែលទទួលការបើកសម្តែងអោយកត់ត្រា ព្រមទាំងពន្យល់ព្រះបន្ទូលរបស់ព្រះជាម្ចាស់ (សូមអានយ៉ូហាន ១៤:២៦ ១៦:១៣ កាឡាទី១:១១-១២)។ សាវ័កប៉ុលកត់ត្រាទុក ព្រមទាំងបកស្រាយបទគម្ពីរបានច្រើនជាងសាវ័កដទៃទៀត។ បួន សាវ័កទទួលអំណាចដ៏ខ្ពង់ខ្ពស់បំផុតពីព្រះអម្ចាស់យេស៊ូវ ដើម្បីរៀបរយក្រុមជំនុំ (សូមអានយ៉ូហាន២០:២២-២៣ ២កូរិនថូស ១០:៨)។ ប្រាំ ពួកសាវ័កទទួលអំណាចដ៏ខ្ពង់ខ្ពស់ពីព្រះអម្ចាស់យេស៊ូវ អាចធ្វើការអស្ចារ្យដូចព្រះអម្ចាស់យេស៊ូវដែរ (សូមអានគម្ពីរម៉ាកុស៦:១៣ លូកា៩:១-២ កិច្ចការ២:៤៣)។ បច្ចុប្បន្ន មិនមាននរណាម្នាក់អាចធ្វើការអស្ចារ្យដូចព្រះអម្ចាស់យេស៊ូវកើតទេ ដ្បិតសំបុត្រ២យ៉ូហាន១០ចែងថា "បើអ្នកណាមកឯអ្នករាល់គ្នា តែមិនបង្រៀនចំពោះសេចក្តីនេះ នោះកុំឱ្យទទួលអ្នកនោះ នៅក្នុងផ្ទះឡើយ កុំឱ្យទាំងជំរាបសួរដល់អ្នកនោះផង"។ ភិនភាគដែលអាចរាប់ថា នរណាម្នាក់ជាសាវ័ករបស់ព្រះអម្ចាស់យេស៊ូវគ្រីស្ទត្រូវធ្វើការអស្ចារ្យផង ត្រូវស្ថិតនៅក្នុងគោលទ្ធិត្រឹមត្រូវផង។ ប្រាំមួយ ដើម្បីអោយទៅជាសាវ័ក បុគ្គលម្នាក់ត្រូវចេះបង្កើតអោយមានក្រុមជំនុំជាលក្ខណៈសកល (សូមអាន ២កូរិនថូស១១:២៨)។ សាវ័កប៉ុលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ដូចសេចក្តីតម្រូវការទាំងប្រាំមួយយ៉ាងខាងលើ បានជាលោកអាចទទួលងារជាសាវ័ករបស់ព្រះអម្ចាស់យេស៊ូវគ្រីស្ទបាន។

"សំបុត្រប៉ុលខ្ញុំ ជាសាវ័ករបស់ព្រះយេស៊ូវគ្រីស្ទ ដោយនូវបំណងព្រះហឫទ័យ

ព្រះ"។ សាវ័កប៉ុលសង្កត់ធ្ងន់ម្តងទៀតថា លោកទទួលនាទីជាសាវ័ករបស់ព្រះអម្ចាស់យេស៊ូវគ្រីស្ទ មិនមែនដោយសារបំណងចិត្តរបស់លោក ក៏មិនមែនដោយសារមានពួកជំនុំណាតែងតាំងលោកដែរ។ លោកបញ្ជាក់ក្នុងគម្ពីរកាឡាទី១:១៥-១៦ថា "ប៉ុន្តែ កាលព្រះដែលរើសខ្ញុំតាំងពីផ្ទៃម្តាយមក ហើយបានហៅខ្ញុំដោយព្រះគុណទ្រង់ បានសព្វព្រះហឫទ័យ នឹងបើកសំដែងព្រះរាជបុត្រាទ្រង់ មកក្នុងខ្ញុំ ដើម្បីឱ្យខ្ញុំបានផ្សាយដំណឹងល្អពីទ្រង់ ដល់ពួកសាសន៍ដទៃ នោះខ្ញុំមិនបានទៅប្រឹក្សានឹងសាច់ឈាមទេ"។ ម្យ៉ាងទៀត លោកសរសេរក្នុងគម្ពីរ១ធីម៉ូថេ១:១២-១៣ដែរថា "ខ្ញុំអរព្រះគុណដល់ព្រះ ដែលទ្រង់ចំរើនកំឡាំងដល់ខ្ញុំ គឺជាព្រះគ្រីស្ទយេស៊ូវ ជាព្រះអម្ចាស់នៃយើងរាល់គ្នា ពីព្រោះទ្រង់បានរាប់ខ្ញុំទុកជាស្មោះត្រង់ ទាំងតាំងខ្ញុំឱ្យមានការងារ ដែលពីដើមខ្ញុំជាអ្នកប្រមាថ ធ្វើទុក្ខបៀតបៀន ហើយព្រហើនឈ្លានពាន តែទ្រង់បានអាណិតមេត្តាដល់ខ្ញុំ ពីព្រោះខ្ញុំបានប្រព្រឹត្តដោយខ្វៅល្ងង់ ឥតមានសេចក្តីជំនឿ"។ មិនតែប៉ុណ្ណោះ លោកបញ្ជាក់នៅក្នុងគម្ពីរ១កូរិនថូស១:១ ២កូរិនថូស១:១ កូល៉ុស១:១ ២ធីម៉ូថេ១:១បន្ថែមទៀតពីជំណើរនេះ។

"ផ្ញើមកពួកបរិសុទ្ធ ដែលនៅក្រុងអេភេសូរ"។ ពាក្យថា "ពួកបរិសុទ្ធ" ក្នុងភាសាក្រេកហៅថា ហាហ្គីយ៉ូសប្រែថា បរិសុទ្ធ ឬមិនលាយឡំ។ ពាក្យថា បរិសុទ្ធមិនមែនមានន័យថា គ្រប់លក្ខណ៍ទេ។ បរិសុទ្ធមានន័យថា ញែកសម្រាប់អោយព្រះជាម្ចាស់ប្រើ។ អ្នកបរិសុទ្ធគឺជាបុគ្គលដែលជឿដល់ព្រះអម្ចាស់យេស៊ូវគ្រីស្ទ ព្រមទាំងញែកខ្លួនសម្រាប់តែអោយព្រះជាម្ចាស់ប្រើតែម្យ៉ាងប៉ុណ្ណោះ។ នៅលើលោកនេះ មាន

មនុស្សពីរពួក គឺអ្នកបរិសុទ្ធ និងអ្នកមិនសូវសុទ្ធ។ បើលោកអ្នកជាអ្នកបរិសុទ្ធ លោកអ្នកមិនមែនជាអ្នកមិនសូវសុទ្ធទេ បើលោកអ្នកមិនជាអ្នកមិនសូវសុទ្ធ លោកអ្នកមិនមែនជាអ្នកបរិសុទ្ធទេ។ សូមកត់ចំណាំដែរថា នៅលើលោកយើងនេះ មានអ្នកបរិសុទ្ធដែលមិនបានញែកខ្លួនសម្រាប់អោយព្រះជាម្ចាស់ប្រើដែរ។ រឿងនេះ ជាកំហុសរបស់ពួកអ្នកបរិសុទ្ធ។ ពួកអ្នកបរិសុទ្ធ គឺជាអ្នកញែកខ្លួនដោយឡែកសម្រាប់អោយព្រះជាម្ចាស់ទ្រង់ប្រើ។ ពួកអ្នកបរិសុទ្ធ គួរប្រព្រឹត្តកិរិយាអោយបានបរិសុទ្ធ។ ប៉ុន្តែ កិរិយាប្រព្រឹត្តអោយបានបរិសុទ្ធ មិនអាចធ្វើអោយបុគ្គលម្នាក់រាប់ថា ជាពួកបរិសុទ្ធទេ។ ព្រះជាម្ចាស់រាប់បុគ្គលម្នាក់ថា ជាអ្នកបរិសុទ្ធ យោលទៅតាមឋានៈរបស់គេនៅក្នុងអង្គព្រះគ្រីស្ទយេស៊ូវ។

"នៅក្រុងអេភេសូរ" ត្រង់នេះ លោកអ្នកអាចសរសេរភូមិស្រុក ឬទីក្រុងដែលលោកអ្នករស់នៅក៏បានដែរ។ ចំពោះខ្ញុំ ខ្ញុំនិយាយថាជាពួកជំនុំ "នៅខេត្តកំពង់ឆ្នាំង"។

"ជាពួកអ្នកស្មោះត្រង់ក្នុងព្រះគ្រីស្ទយេស៊ូវ"។ ពួកអ្នកស្មោះត្រង់ក្នុងព្រះគ្រីស្ទយេស៊ូវ គឺជាពួកអ្នកដែលជឿដល់ព្រះអម្ចាស់យេស៊ូវគ្រីស្ទ។ អ្នកជឿដល់ព្រះអម្ចាស់យេស៊ូវគ្រីស្ទមានលក្ខណៈដូចជាពួកបរិសុទ្ធដែរ។ ពួកបរិសុទ្ធ ជាឋានៈដែលព្រះជាម្ចាស់ផ្តល់មកសម្រាប់អ្នកជឿ។ ឯ "អ្នកជឿ" វិញ គឺជាងារដែលមនុស្សលោកដាក់អោយអ្នកព្រមជើរតាមព្រះអម្ចាស់យេស៊ូវគ្រីស្ទ។

"ក្នុងព្រះគ្រីស្ទយេស៊ូវ"។ ពាក្យ "ក្នុង" ញុំាងអោយមនុស្សម្នាក់មានលក្ខណៈ

សម្បត្តិខុសពីគេដូចមេឃហើយនិងដី។ ពាក្យ "ក្នុងព្រះយេស៊ូវគ្រីស្ទ" បញ្ជាក់ថា បុគ្គលម្នាក់បានទទួលសេចក្តីសង្គ្រោះរួចហើយ។ តើធ្វើដូចម្តេចដើម្បីអោយដឹងថា បុគ្គលម្នាក់បានទទួលសេក្តីសង្គ្រោះ? កាលណាបុគ្គលម្នាក់រស់នៅក្នុងព្រះគ្រីស្ទយេស៊ូវ អ្នកនោះបានទទួលសេចក្តីសង្គ្រោះហើយ។ គម្ពីរ១កូរិនថូស១២:១២-១៣ សម្តែងថា បន្ទាប់ពីយើងជឿដល់ព្រះអម្ចាស់យេស៊ូវគ្រីស្ទ ព្រះអង្គប្រទានអោយយើងបានទទួលការជ្រមុជដោយព្រះវិញ្ញាណបរិសុទ្ធ។ ការជ្រមុជដោយព្រះវិញ្ញាណបរិសុទ្ធ គឺជាការញែកអ្នកជឿម្នាក់ដាក់បញ្ចូលទៅក្នុងរូបកាយរបស់ព្រះអង្គ។ គម្ពីរ១កូរិនថូស៦:១៧បញ្ជាក់បន្ថែមដើម្បីគាំទ្រចំណុចខាងលើ។ មិនតែប៉ុណ្ណោះ គម្ពីររ៉ូម៨:១ចែងថា "ហេតុនោះ នៅជាន់នេះ អ្នកណាដែលនៅក្នុងព្រះគ្រីស្ទយេស៊ូវ នោះគ្មានទោសសោះ"។ ដូច្នេះ ជនណាក៏ដោយដែលនៅក្នុងព្រះគ្រីស្ទយេស៊ូវ ជននោះបានទទួលសេចក្តីសង្គ្រោះពិតប្រាកដហើយ។ ពាក្យ "ក្នុង" មានប្រើចំនួន១៣០ដង ក្នុងព្រះគម្ពីរសញ្ញាថ្មីទាំងមូល។ ពាក្យ "ក្នុង" ប្រើ ជាអាទិ៍ក្នុងគម្ពីរយ៉ូហាន១៥:៤ ដែលចែងថា "ចូរនៅជាប់នឹងខ្ញុំ ហើយខ្ញុំជាប់នឹងអ្នករាល់គ្នាចុះ ប្រៀបដូចជាខ្នែង បើមិននៅជាប់នឹងគល់ នោះពុំអាចនឹងបង្កើតផលដោយឯកឯងបានទេ ដូច្នេះ អ្នករាល់គ្នាក៏ពុំបានដែរ លើកតែនៅជាប់នឹងខ្ញុំ"។ កាលណាបុគ្គលម្នាក់នៅ "ក្នុង" ព្រះអម្ចាស់យេស៊ូវហើយ បុគ្គលនោះបានទទួលសេចក្តីសង្គ្រោះជាស្ថាពរ។ យើងមិអាចយល់ពីជម្រៅនៃពាក្យនេះអោយបានច្បាស់លាស់ទេ។ យើងគ្រាន់តែជឿដល់ព្រះអម្ចាស់យេស៊ូវគ្រីស្ទតែប៉ុណ្ណោះ។ បុគ្គលណាដែលនៅក្នុងព្រះអម្ចាស់យេស៊ូវ បុគ្គលនោះបានទទួលសេចក្តីសង្គ្រោះរួចហើយ។

"សូមឱ្យអ្នករាល់គ្នាបានប្រកបដោយព្រះគុណ និងសេចក្តីសុខសាន្ត..."។ "ព្រះគុណ" ជាពាក្យដែលមនុស្សរស់នៅសម័យសាវ័កប៉ុលនិយាយ ដើម្បីជម្រាបសួរគ្នាទៅវិញទៅមក។ រីឯពាក្យសេចក្តីសុខសាន្តវិញ ជាពាក្យជម្រាបសួរគ្នាខាងសាសនា។ ពាក្យនេះសាសន៍យូដានិយមប្រើជាងគេ។ នៅក្នុងភាសាហេព្រើរពាក្យថា សន្តិភាព គឺពាក្យស្ហាឡុម។ សាវ័កប៉ុលប្រើពាក្យទាំងពីរនេះ ក្នុងការជម្រាបសួរដល់ពួកជំនុំ។ ពាក្យទាំងពីរនេះមានខ្លឹមសារយ៉ាងជ្រាលជ្រៅជាទីបំផុត។ ព្រះគុណ ជាមធ្យោបាយដែលព្រះជាម្ចាស់ប្រើ ដើម្បីសង្គ្រោះដល់មនុស្សលោក។ លោកអ្នកចាំបាច់ត្រូវស្គាល់ព្រះគុណរបស់ព្រះជាម្ចាស់ជាមុន ទើបលោកអ្នកទទួលសេចក្តីសុខសាន្តពីព្រះមកជាក្រោយ។ សាវ័កប៉ុលប្រើព្រះគុណ មុនសេចក្តីសុខសាន្ត។ គម្ពីរ៉ូម៥:១លោកសរសេរថា "ដូច្នេះដែលយើងរាល់គ្នាបានរាប់ជាសុចរិត ដោយការជឿ នោះឈ្មោះថាយើងបានមេត្រីនឹងព្រះ ដោយសារព្រះយេស៊ូវគ្រីស្ទ ជាព្រះអម្ចាស់នៃយើងរាល់គ្នាហើយ"។

សេចក្តីសុខជាសេចក្តីប្រាថ្នារបស់មនុស្សគ្រប់រូប របស់សត្វគ្រប់ប្រភេទ របស់ធម្មជាតិដែលមាននៅជុំវិញខ្លួនមនុស្សលោក។ នៅទីណា ក៏គេនិយាយពីសេចក្តីប្រាថ្នាចង់បានសេចក្តីសុខដែរ។ ក្នុងវិស័យសាសនា វិស័យសង្គម ក៏គេចង់បានសុខ នៅក្នុងវិស័យនយោបាយគេចង់អោយពិភពលោកនេះមានសុខសន្តិភាព។ សត្វចង់រស់នៅ មិនចង់អោយអ្នកណារំខានវា មនុស្សរស់នៅ មិនចង់អោយនរណារំខានគេដែរ។ ប៉ុន្តែទោះបីមនុស្សលោកចង់បានសន្តិភាពយ៉ាងណាក៏ដោយ ពិភពលោកមិនមានសេចក្តីសុខសាន្តដូចគំនិតមនុស្សប្រាថ្នាចង់បានទេ។ តើរឿងនេះមកពីមូលហេតុអ្វី? នៅលើលោក

យើងនេះ គ្មានសេចក្តីសុខសាន្តសន្តិភាពទេ បើមិនបានស្គាល់ព្រះគុណរបស់ព្រះជាម្ចាស់ជាមុនសិន។ នៅក្នុងចំណោមសេចក្តីប្រាថ្នារបស់មនុស្សជាតិ គេមិនសូវប្រាថ្នាចង់បានព្រះគុណទេ គឺគេចង់បានតែសេចក្តីស្រឡាញ់ និងសន្តិភាពតែប៉ុណ្ណោះ។ ពាក្យទាំងពីរម៉ាត់នេះ ជាពាក្យដែលមានដើមកំណើតពីព្រះបន្ទូលរបស់ព្រះជាម្ចាស់។ សេចក្តីសុខសាន្ត ជាសេចក្តីសុខដែលព្រះជាម្ចាស់បានអត់ទោសអំពើបាបដល់យើង។ មនុស្សលោកមិនអាចទទួលការអត់ទោសបាប បើមិនទទួលស្គាល់ពីព្រះគុណរបស់ព្រះជាម្ចាស់ ដែលបានផ្តល់មកមនុស្សលោកតាមរយៈព្រះអម្ចាស់យេស៊ូវគ្រីស្ទ។

"...នឹងសេចក្តីសុខសាន្ត អំពីព្រះជ័យជាព្រះវរបិតានៃយើង ហើយអំពីព្រះអម្ចាស់យេស៊ូវគ្រីស្ទ"។ ព្រះគុណ និងសេចក្តីសុខសាន្ត មានដើមកំណើតមកពីព្រះជ័យជាព្រះវរបិតា។ នៅពេលបុគ្គលម្នាក់ព្រមទទួលព្រះគុណរបស់ព្រះ ព្រះវិញ្ញាណបរិសុទ្ធព្រះអង្គបានបំផ្លាស់បំប្រែជននោះអោយទៅជាកូនរបស់ព្រះ។ ដូច្នេះ ព្រះគុណទទួលបានមកពីព្រះជ័យជាព្រះវរបិតា។ ព្រះគុណ និងសេចក្តីសុខសាន្តក៏មានដើមកំណើតមកពីអង្គព្រះយេស៊ូវគ្រីស្ទដែរ។ ចុះអង្គព្រះវិញ្ញាណបរិសុទ្ធ តើទ្រង់ប្រទានព្រះគុណនឹងសេចក្តីសុខសាន្តដែរឬទេ? សាវ័កប៉ុលបញ្ជាក់ថា ព្រះជាម្ចាស់ប្រទានព្រះវិញ្ញាណបរិសុទ្ធមកដល់ពួកអ្នកជឿ ដើម្បីរក្សាអ្នកជឿ អោយនៅតែមានជំនឿលើព្រះអម្ចាស់ជានិច្ច។ ព្រះវរបិតា និងព្រះរាជបុត្រាជាអង្គដែលផ្តល់ព្រះគុណ និងសេចក្តីសុខសាន្ត។ ព្រះវិញ្ញាណបរិសុទ្ធជាអង្គដែលរក្សាពួកជំនុំ អោយនៅតែស្មោះត្រង់ជាមួយព្រះអង្គ។ យើងត្រូវចែកភូមិសាស្ត្រផ្នែកទេវសាស្ត្រនេះអោយបានហ្មត់ចត់ ដើម្បីកុំអោយទេវសាស្ត្ររបស់យើងចេះ

តែច្របូកច្របល់។

ព្រះដ៏ជាព្រះវរបិតាធ្វើគម្រោងការសម្រាប់ក្រុមជំនុំ

ឥឡូវនេះ យើងឈានមកដល់វគ្គទីពីរនៅក្នុងគម្ពីរអេភេសូរជំពូក១ហើយ។ វគ្គទីពីរចាប់ផ្តើមដោយខគម្ពីរមួយដែលមានខ្លឹមសារយ៉ាងជ្រាលជ្រៅជាទីបំផុត។

សូមសរសើរដល់ព្រះដ៏ជាព្រះវរបិតានៃព្រះយេស៊ូវគ្រីស្ទ ជាព្រះអម្ចាស់នៃយើងរាល់គ្នា ដែលទ្រង់បានប្រទានពរមកយើងក្នុងព្រះគ្រីស្ទ ដោយគ្រប់ទាំងព្រះពរខាងព្រលឹងវិញ្ញាណ នៅស្ថានដ៏ខ្ពស់ (អេភេសូរ១:៣)។

សូមលោកអ្នកកត់ចំណាំអោយបានច្បាស់ នូវពាក្យដែលព្រះបន្ទូលព្រះអង្គសម្តែងក្នុងខខាងលើ។ ព្រះជាម្ចាស់ប្រទានពរដល់យើង។ យើងអាចថ្វាយពាក្យសរសើរដល់ព្រះជាម្ចាស់ពីបបូរមាត់របស់យើងបាន មិនមែនដោយសារចិត្តយើងមានចិត្តចង់សរសើរតម្កើងព្រះអង្គទេ ពីព្រោះព្រះជាម្ចាស់បានប្រទានពរដល់យើងជាមុន។ ព្រះជាម្ចាស់ប្រកាសថា ទ្រង់ប្រទានពរដល់អស់អ្នកណាដែលជឿដល់ព្រះអង្គ។ ពររបស់ទ្រង់មានដល់មនុស្សលោកជាដុំកំភួនដែលយើងអាចចាប់កាន់បាន។ ដោយសារព្រះអង្គ

ប្រទានពរដល់យើង យើងអាចថ្វាយពរដល់ព្រះនាមទ្រង់។ ព្រះអង្គធ្វើអោយយើងជាអ្នក ចានប្រកបដោយព្រះពររបស់ទ្រង់។ ពាក្យថាពរ មានន័យថា សុភមង្គល និងអំណរ។ ព្រះជាម្ចាស់មានព្រះហឫទ័យរីករាយចំពោះមនុស្សដែលចានទទួលព្រះអង្គ ជាអង្គ សង្គ្រោះ។ ព្រះអង្គមានព្រះហឫទ័យរីករាយ ពីព្រោះព្រះអង្គចានរៀបផ្លូវដើម្បីអោយ យើងទទួលសេចក្តីសង្គ្រោះពីព្រះអង្គ រួចហើយព្រះអង្គប្រទានពរដល់យើង។ បន្ទាប់ពី ព្រះអង្គប្រទានពរដល់យើង យើងអាចថ្វាយដល់ព្រះអង្គវិញ។ សេចក្តីនេះមានខ្លឹមសារ យ៉ាងជ្រាលជ្រៅណាស់។ ព្រះពរដែលព្រះជាម្ចាស់ប្រទានមកដល់យើង ឥតមានកំណត់ ទេ។ ព្រះអង្គប្រទានពររាប់ពាន់ រាប់ម៉ឺន រាប់លាន រាប់កោដិ ដល់អស់អ្នកណាដែលជឿ ដលព្រះអង្គ។ អ្នកណាដែលនៅក្នុងព្រះគ្រីស្តយេស៊ូវ ព្រះជាម្ចាស់ប្រទានពរដល់អ្នក នោះ។

"...ដោយគ្រប់ទាំងព្រះពរខាងព្រលឹងវិញ្ញាណ នៅស្ថានដ៏ខ្ពស់"។ សូមយើង កត់ចំណាំពាក្យ "នៅស្ថានដ៏ខ្ពស់"។ ពាក្យថា ស្ថានដ៏ខ្ពស់ ជាពាក្យដែលសម្តែងថា ពី កន្លែងដែលព្រះអម្ចាស់យេស៊ូវគ្រីស្តគង់នៅ។ អ្នកនៅក្នុងព្រះគ្រីស្តយេស៊ូវ ចានទទួល គ្រប់ទាំងព្រះពរខាងព្រលឹងវិញ្ញាណនៅស្ថានដ៏ខ្ពស់។ ខ្ញុំមិនដឹងថា ស្ថានដ៏ខ្ពស់ស្ថិត នៅទីណាទេ។ ប៉ុន្តែ ខ្ញុំដឹងច្បាស់ថា នៅស្ថានដ៏ខ្ពស់ មានព្រះយេស៊ូវគង់នៅទីនោះ។ នៅស្ថានដ៏ខ្ពស់ ព្រះអម្ចាស់យេស៊ូវគ្រីស្តគង់នៅទីខាងស្តាំព្រះវរបិតា។ ម្យ៉ាងទៀត យើងដឹងដោយសារព្រះបន្ទូលរបស់ព្រះជាម្ចាស់សម្តែងថា ព្រះជាម្ចាស់ប្រទានពរដល់ យើង កាលណាយើងនៅក្នុងព្រះគ្រីស្តយេស៊ូវ។

សូមលោកអ្នកកត់ចំណាំខនេះអោយបានច្បាស់។ ខនេះមិនបានចែងថា "ទ្រង់បានប្រទានពរមកយើងជាមួយនឹងព្រះគ្រីស្ទ ដែលគ្រប់ទាំងព្រះពរខាងព្រលឹងវិញ្ញាណនៅស្ថានដ៏ខ្ពស់ទេ"។ ព្រះជាម្ចាស់ប្រទានពរយើងក្នុងព្រះគ្រីស្ទ។ ពាក្យថា ក្នុងព្រះគ្រីស្ទ មានន័យថា ក្នុងវិនាទីដែលលោកអ្នកកំពុងរស់នៅនេះ លោកអ្នកមានសិទ្ធិអង្គុយនៅស្ថានដ៏ខ្ពស់ក្នុងព្រះគ្រីស្ទយេស៊ូវ។ កាលណាយើងនិយាយថា ព្រះជាម្ចាស់ប្រទានពរដល់យើងជាមួយព្រះគ្រីស្ទមានន័យថា យើងអង្គុយលើបល្ល័ង្កខាងស្តាំព្រះវរបិតាជំនួសព្រះគ្រីស្ទហើយ។ យើងទទួលព្រះពរខាងព្រលឹងវិញ្ញាណនៅស្ថានដ៏ខ្ពស់ក្នុងព្រះគ្រីស្ទ។ ឃ្លានេះមានន័យថា ក្នុងនាមយើងជាអ្នកជឿដល់ព្រះអម្ចាស់យេស៊ូវគ្រីស្ទ ព្រះជាម្ចាស់ប្រទានគ្រប់ទាំងព្រះពរខាងព្រលឹងវិញ្ញាណនៅស្ថានដ៏ខ្ពស់ ដល់យើងក្នុងព្រះគ្រីស្ទ ពោលគឺ យើងអាចរស់នៅស្ថានសួគ៌ក្នុងពេលដែលយើងកំពុងរស់នៅលើផែនដី។ បើមានគេសួរលោកអ្នកថា "តើដែលជឿដល់ព្រះអម្ចាស់យេស៊ូវគ្រីស្ទសព្វថ្ងៃនេះ លោកអ្នកសង្ឃឹមថា បានទៅស្ថានសួគ៌មែនឬ?" ខ្ញុះឆ្លើយថា ខ្ញុំសង្ឃឹមថា ខ្ញុំបានទៅស្ថានសួគ៌។ លោកអ្នកបងប្អូនអើយ គម្ពីរខាងលើចែងថា "...ទ្រង់បានប្រទានពរមកយើងក្នុងព្រះគ្រីស្ទ ដោយគ្រប់ទាំងព្រះពរខាងព្រលឹងវិញ្ញាណនៅស្ថានដ៏ខ្ពស់"។ ខគម្ពីរនេះបញ្ជាក់ថា កាលណាយើងជឿដល់ព្រះអម្ចាស់យេស៊ូវគ្រីស្ទ យើងពិតជាបាននៅស្ថានសួគ៌ ចាប់ផ្តើមពីក្នុងវិនាទី ដែលយើងបានជឿដល់ព្រះអម្ចាស់យេស៊ូវគ្រីស្ទ ជាអង្គសង្គ្រោះ។ ឋាន: ដែលយើងទទួលបាននេះ គឺបានដោយសារព្រះអម្ចាស់យេស៊ូវគ្រីស្ទ។ ដូច្នេះ បានជានៅក្នុងព្រះគ្រីស្ទ ព្រះជាម្ចាស់ប្រទានគ្រប់ព្រះពរខាងព្រលឹងវិញ្ញាណនៅស្ថានដ៏ខ្ពស់ដល់

យើងរាល់គ្នា។

"សូមសរសើរដល់ព្រះដ៏ជាព្រះវរបិតានៃព្រះយេស៊ូវគ្រីស្ទ..."។ យើងអាចថ្វាយពាក្យសរសើរដល់ព្រះដ៏ជាព្រះវរបិតា និងដល់ព្រះរាជបុត្រារបស់ទ្រង់។ យើងមានឯកសិទ្ធិអាចថ្វាយពាក្យសរសើរដល់ព្រះដ៏ជាព្រះវរបិតា ពីព្រោះដំបូងឡើយ ព្រះអង្គប្រទានពរដល់យើងជាមុន។ ព្រះអង្គប្រទានពរដល់យើងនៅគ្រប់ទាំងព្រះពរខាងព្រលឹងវិញ្ញាណនៅស្ថានដ៏ខ្ពស់។ នៅក្នុងព្រះគម្ពីរសញ្ញាចាស់ មានរឿងដូចគ្នានេះដែរ។ លោកយ៉ូស្វេត្រូវជីកនាំសាសន៍អ៊ីស្រាអែលចូលទៅទឹកដីកាណាន។ ទឹកដីកាណាន មិនមែនជាស្ថានសួគ៌ទេ គ្រាន់តែជាស្ថានដែលមនុស្សលោករស់នៅសព្វថ្ងៃ។ គ្រីស្ទបរិស័ទមានឈ្មោះកត់ទុកនៅស្ថានសួគ៌ មានអភ័យឯកសិទ្ធិអាចទទួលបានព្រះពរនៅស្ថានដ៏ខ្ពស់ក្នុងព្រះគ្រីស្ទក៏ពិតមែន។ ប៉ុន្តែ ដរាបណាជីវិតយើងរស់នៅលើលោកនេះនៅឡើយ គ្រីស្ទបរិស័ទត្រូវយកជ័យជំនះលើសត្រូវ ដែលចង់ទាញយើងអោយដើរនៅក្នុងលោកីយ៍នេះវិញ។ នៅក្នុងលោកនេះ គ្រីស្ទបរិស័ទមានសមរភូមិដែលត្រូវប្រយុទ្ធតតាំង មានអំពើអាក្រក់ដែលត្រូវយកឈ្នះ។ ពេលណាយើងឡើងទៅដល់ស្ថានសួគ៌ យើងមិនមានសមរភូមិណា មិនមានសត្រូវណាដែលយើងចាំបាច់យកឈ្នះទៀតទេ។ សព្វថ្ងៃនេះយើងកំពុងដើរនៅក្នុងទឹកដីកាណាននៅឡើយ។ យើងចាំបាច់ត្រូវពឹងពាក់ដល់ព្រះអម្ចាស់យេស៊ូវគ្រីស្ទជារៀងរាល់ដង្ហើមចេញចូលរបស់យើង។

លោកអ្នកបងប្អូនអើយ ព្រះជាអម្ចាស់ប្រទានគ្រប់ទាំងព្រះពរខាងព្រលឹងវិញ្ញាណនៅស្ថានដ៏ខ្ពស់ដល់យើងក្នុងព្រះគ្រីស្ទយេស៊ូវ។ តើព្រះពរនោះមានទ្រង់ទ្រាយ

បែបណា? ព្រះពរនោះមានទ្រង់ទ្រាយដូចអង្គព្រះគ្រីស្ទយេស៊ូវ។ ព្រះគ្រីស្ទសុគតជំនួសអំពើបាបរបស់យើង ហើយទ្រង់រស់ឡើងវិញ ដើម្បីផ្តល់នូវភាពសុចរិតដល់យើង។ បន្ទាប់ពីយើងទទួលភាពសុចរិតពីព្រះជាម្ចាស់ហើយ ព្រះវិញ្ញាណបរិសុទ្ធរបស់ព្រះអង្គញែកយើង មិនអោយយើងមានការលាយឡំនឹងភាពមិនបរិសុទ្ធផ្សេងៗទៀត។ បន្ទាប់ពីយើងជឿដល់ព្រះអម្ចាស់យេស៊ូវគ្រីស្ទហើយ យើងមិនអាចរស់នៅដោយកម្លាំងយើងអោយបានបរិសុទ្ធថ្វាយព្រះជាម្ចាស់ទេ។ ម្យ៉ាងវិញទៀត មនុស្សថ្មីដែលយើងបានទទួលជឿព្រះអម្ចាស់យេស៊ូវ ក៏គ្មានកម្លាំងអ្វីដោយខ្លួនឯងដែរ។ យើងជាអ្នកជឿដល់ព្រះអម្ចាស់យេស៊ូវគ្រីស្ទ ត្រូវពឹងពាក់លើចេស្តារបស់ព្រះវិញ្ញាណបរិសុទ្ធដើម្បីជីកនាំយើង។ ការពឹងពាក់នេះ មិនមែនកើតឡើងដោយសារយើងខំប្រឹងពឹងពាក់លើខ្លួនឯងនោះទេ គឺដោយសារព្រះពរដែលព្រះជាម្ចាស់ប្រទានដល់យើងវិញ។ តើយើងមានអ្វីអាចប្រៀបផ្ទឹមនឹងព្រះជាម្ចាស់យើងបានដែរឬទេ? ព្រះជាម្ចាស់ប្រទានពរដល់យើងក្នុងព្រះគ្រីស្ទពេលបច្ចុប្បន្ននេះ។ លោកអ្នកមិនចាំបាច់រង់ចាំដល់លោកអ្នកស្លាប់ហើយ ទើបបានទទួលព្រះពរនោះទេ។ លោកអ្នកទទួលព្រះពរខាងព្រលឹងវិញ្ញាណនៅស្ថានដ៏ខ្ពស់ក្នុងពេលបច្ចុប្បន្ននេះ ពោលគឺក្នុងពេលដែលលោកអ្នកកំពុងរស់នៅលើផែនដីនៅឡើយ។ នៅពេលដែលលោកអ្នកកំពុងរស់នៅ ព្រះជាម្ចាស់ប្រទានគ្រប់ទាំងព្រះពរខាងព្រលឹងវិញ្ញាណ នៅស្ថានដ៏ខ្ពស់ដល់លោកអ្នក។ ពេលលោកអ្នកទទួលព្រះអម្ចាស់យេស៊ូវគ្រីស្ទ លោកអ្នកមានអ្វីៗទាំងអស់ ដែលព្រះអម្ចាស់យេស៊ូវមាននៅក្នុងជីវិតនេះហើយ។

យើងស្លេះការសិក្សាគម្ពីរអេភេសូរត្រឹមណេះសិនចុះ។ ទំរាំយើងជួបគ្នាលើកក្រោយ សូមព្រះជាម្ចាស់ប្រទានពរដ៏ធំឧត្តម ដល់លោកអ្នកបងប្អូនគ្រប់ៗគ្នា។ "ជើរជាមួយនឹងព្រះ ពិតជាប្រទះនឹងព្រះយេស៊ូវជាមិនខាន!"